ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
សាលាខេត្តព្រៃវែង
លេខ ០១១ / ស៊ូ៧ / ១១

# សេចក្តីជូនដំណឹង
## ស្តីពី
## ការប្រមូល និង ការត្រួតពិនិត្យពន្ធប៉ាតង់

- បានឃើញក្រឹត្យច្បាប់លេខ ២២ ក្រ.ច ចុះថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ១៩៨៥ របស់ក្រុមប្រឹក្សារដ្ឋ ស្តីពីពន្ធប៉ាតង់
- បានឃើញប្រកាសលេខ ១២៦០ កហវ ចុះថ្ងៃទី ០៣/០៧/១៩៨៥ ស្តីពីការណែនាំអនុវត្តក្រឹត្យច្បាប់ស្តីពីពន្ធប៉ាតង់
- បានឃើញសារាចរណែនាំលេខ ០០៤ កហវ ចុះថ្ងៃទី ១៤/១១/២០០៧ ស្តីពីការអនុវត្តន៍ពន្ធប៉ាតង់
- បានឃើញសេចក្តីជូនដំណឹងលេខ ០០៥ សជណ.កហវ.ពដ ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីបទប្បញ្ញត្តិទាំងឡាយស្តីពីពន្ធអាករ ដែលប្រមូលដោយអង្គការពន្ធ។

អភិបាលនៃគណៈអភិបាលខេត្តសូមជូនដំណឹងថា៖

១- ពន្ធប៉ាតង់ជាពន្ធប្រចាំឆ្នាំ ត្រូវចាប់ផ្តើមប្រមូល និងប្រមូលឲ្យអស់នៅដើមឆ្នាំ យ៉ាងយឺតបំផុត នៅថ្ងៃទី ៣១ ខែមិនា នៃឆ្នាំនីមួយៗ។

២- អាជីវកម្មដ្ឋានដែលប្រកបមុខរបរច្រើនប្រភេទ ត្រូវបង់ពន្ធប៉ាតង់ផ្សេងៗគ្នា ទៅតាមមុខរបរនីមួយៗ។

៣- អាជីវកម្មដ្ឋានដែលមានសាខានៅខេត្តតែមួយ ដែលរួមគ្នាលក់ដូរ ឬផលិតទំនិញដូចគ្នា មិនចាំបាច់បង់ពន្ធប៉ាតង់ផ្សេងគ្នាទេ។ ប្រសិនបើអាជីវកម្មដ្ឋានដែលមានសាខានៅតាមខេត្តផ្សេងគ្នា ត្រូវបង់ពន្ធប៉ាតង់នៅខេត្ត ដែលសាខានោះស្ថិតនៅ។

៤- ប័ណ្ណប៉ាតង់មានតម្លៃតែចំពោះអ្នកដែលមានឈ្មោះក្នុងប័ណ្ណប៉ាតង់តែប៉ុណ្ណោះ។ ករណីមានការផ្លាស់ប្តូរទីកន្លែង ឬ ផ្លាស់ប្តូរមុខរបរអាជីវកម្មថ្មី ឬ ផ្លាស់ប្តូរម្ចាស់ ត្រូវបង់ពន្ធប៉ាតង់ជាថ្មីម្តងទៀត។

៥- នៅពេលឈប់ប្រកបអាជីវកម្ម អាជីវករត្រូវប្រគល់ប័ណ្ណប៉ាតង់ឲ្យអង្គការពន្ធវិញ។

៦- អាជីវករដែលចូលរួមដេញថ្លៃនូវមុខរបរផ្សេង ក្រៅពីប្រភេទមុខរបរដែលខ្លួនបានបង់ប៉ាតង់រួចហើយ អាជីវករនោះត្រូវបង់ពន្ធប៉ាតង់សម្រាប់ប្រភេទមុខរបរថ្មីម្តងទៀត ទើបអាចចូលដេញថ្លៃបាន។

៧- ករណីបង់ពន្ធប៉ាតង់មិនទាន់ពេលវេលាកំណត់ ត្រូវទទួលរងការប្រាក់យឺតយ៉ាវ ២% ក្នុង១ខែ លើប្រាក់ពន្ធ ដែលត្រូវបង់។

៨- នៅករណីស្ថាប័នមានសមត្ថកិច្ចត្រួតពិនិត្យឃើញថា បានប្រព្រឹត្តអំពើរាំងស្ទះស្តីពីការអនុវត្តន៍បទប្បញ្ញត្តិស្តីពីពន្ធដារ ពន្ធបន្ថែមត្រូវកំណត់ដូចខាងក្រោមនេះ សម្រាប់អំពើនីមួយៗ៖
   ក- ២.០០០.០០០រៀល(ពីរលានរៀល) ចំពោះអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកក្រោមរបបពិត ឬមន្ត្រីរាជការ។
   ខ- ៥០០.០០០រៀល(ប្រាំរយពាន់រៀល) ចំពោះអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកក្រោមរបបបំព្រួញ ឬរបបម៉ៅការ។

ទទួលបាននូវសេចក្តីជូនដំណឹងនេះ អភិបាលនៃគណៈអភិបាលខេត្តមានជំនឿថា គ្រប់អាជីវករទាំងអស់នឹងបំពេញកាតព្វកិច្ចបង់ពន្ធប៉ាតង់ ទៅតាមការកំណត់ខាងលើជាមិនខានឡើយ។

ព្រៃវែង,ថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០១១
**អភិបាលនៃគណៈអភិបាលខេត្ត**

**អ៊ុង_សាមី**

**កន្លែងទទួល៖**
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានពន្ធដារ
- ក្រុមប្រឹក្សាខេត្តព្រៃវែង "គោរពជូនជ្រាប"
- សាលាស្រុក-ក្រុង
- សាខាពន្ធដារខេត្ត
- និងស្ថាប័នពាក់ព័ន្ធ "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ